ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២២ លេខ៦៦ ត្រីមាសទី០៣ ឆ្នាំ២០២២

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារធាតុ

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១០-១២-២០២២ -ព្រះរាជក្រម នស/រកម/១២២២/០១៤ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ៨០៦៧


### ២~ព្រះរាជក្រឹត្យ


១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៧៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **គួ ឆៃរ៉ុង** (GUO ZAIRONG) ជនជាតិចិន សញ្ជាតិចិន ៨១៣៦

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៧៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ១៨រូប ៨១៣៧

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៧៧ ស្តីពី ការផ្ទេរបញ្ចូលក្របខ័ណ្ឌលោក **ហ៊ីរ មិថុនា** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៨១៣៩

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៧៨ ស្តីពី ការនិយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់លោក **ឆាង ឆៃ** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៨១៤០

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៧៩ ស្តីពី ការផ្ទេរបញ្ចូលក្របខ័ណ្ឌលោក **ម៉ែន អេង** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៨១៤១

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៨០ ស្តីពី ការផ្ទេរបញ្ចូលក្របខ័ណ្ឌលោក **សា ស៊ីថា** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៨១៤២

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៨១ ស្តីពី ការផ្ទេរបញ្ចូលក្របខ័ណ្ឌលោក **កៅ សុវណ្ណារិទ្ធ** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៨១៤៣

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៨២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩ រូប ៨១៤៤

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៨៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ស្វី ស៊ីនហ័ង** (SHWEE SIN HAUNG) ជនជាតិមីយ៉ាន់ម៉ា សញ្ជាតិមីយ៉ាន់ម៉ា ៨១៤៥

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៨៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ចាង ជីជា** (ZHANG, ZIJIE) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ស្កាយ អូស៊ាន** (SKY OCEAN) ៨១៤៦

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៨៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ការប៉ាឈីវ អ៊ីហ្គរ** (KARPACHEV IGOR) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី ៨១៤៧

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៨៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **យាន ជីនអ៊ី** (YUAN, JINYI) ជនជាតិចិន សញ្ជាតិចិន ៨១៤៨

១៧-៨-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៨២២/៩៨៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ជីង ហេនរី** (GING HENRY) ជនជាតិដូមីនីក សញ្ជាតិដូមីនីក ដោយប្តូរឈ្មោះជា **គិត បូរ៉ាន់** (KITH BORAN) ៨១៤៩


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


៤-១១-២០២២ -អនុក្រឹត្យលេខ ២៣៣ អនក្រ.បក ស្តីពី និរាករណ៍អនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី ការប្រគល់ភារកិច្ចនិងសិទ្ធិក្នុងការលក់និងធ្វើការនាំចេញផលិតផលកៅស៊ូជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៨១៥០

១៤-១១-២០២២ -អនុក្រឹត្យលេខ ២៣៤ អនក្រ.បក ស្តីពី ការចេញផ្សាយធនប័ត្រ ប្រភេទ ២០០ រៀល គំរូថ្មី ៨១៥២

១៤-១១-២០២២ -អនុក្រឹត្យលេខ ២៣៥ អនក្រ.បក ស្តីពី ការចេញផ្សាយធនប័ត្រ ប្រភេទ ២០០០ រៀល គំរូថ្មី ៨១៥៣

១៦-១១-២០២២ -អនុក្រឹត្យលេខ ២៣៦ អនក្រ.បក ស្តីពី ការបន្ថែមឥណទានថវិកា ៨១៥៤

១៩-៨-២០២២ -អនុក្រឹត្យលេខ ៦៨២ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៨១៥៦

១៩-៨-២០២២ -អនុក្រឹត្យលេខ ៦៨៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៨១៥៩

២២-៨-២០២២ -អនុក្រឹត្យលេខ ៦៨៤ អនក្រ.តត ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា ៨១៦០


### ២~សេចក្តីសម្រេច


២៨-១១-២០២២ -សេចក្តីសម្រេចលេខ ៨០ សសរ ស្តីពី ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំលើកទី១២ ស្តីពី កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ៨១៦២


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


៩-១២-២០២២ -ប្រកាសលេខ ៩១៣ សហវ.ប្រក ស្តីពី ការបង្កើតក្រុមការងារប្រតិបត្តិកិច្ចការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមចំណុះ ៨១៦៦

## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


| | | |
|---|---|---|
| ៥-៨-២០២២ | -ប្រកាសលេខ ៣៣១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហាវ ជា លី (ខេមបូឌា) ហ្គាម៉ិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៨១៧០ |
| ១១-៨-២០២២ | -ប្រកាសលេខ ៣៣២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឌុក វើលដ៍ ថយស៍ ឯ.ក បង្កើតរោងចក្រ ផលិតតុក្កតា និងប្រដាប់ប្រដាក្មេងលេងគ្រប់ប្រភេទ | ៨១៧៣ |
| ១១-៨-២០២២ | -ប្រកាសលេខ ៣៣៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជេភី សាន់នី ប្រដាក់ ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ | ៨១៧៦ |


## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


| | | |
|---|---|---|
| ២-៩-២០២១ | -ប្រកាសលេខ ០៩១៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លេខ ០៩១៧ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០២១ | ៨១៧៩ |
| ២-៩-២០២១ | -ប្រកាសលេខ ០៩១៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ លេខ ០៩១៨ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០២១ | ៨១៨៣ |
| ២-៩-២០២១ | -ប្រកាសលេខ ០៩១៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ លេខ ០៩១៩ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០២១ | ៨១៨៧ |

# ព្រះរាជក្រម

នស/រកម/១២២២/ ០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ
# សម្រាប់ការគ្រប់គ្រង
# ឆ្នាំ២០២១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ
## ផ្នែកទី១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១ .-**

ត្រូវបានយល់ព្រមលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០។

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក១**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា២ .-**

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................២៦ ២៥០ ៣៣៦,០ លានរៀល
- អនុវត្តជាក់ស្តែង....................................២៦ ៩០៨ ៩៨៣,៥ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានខ្ពស់ជាង
ច្បាប់ហិរញ្ញវត្ថុ............................................... ៦៥៨ ៦៤៧,៥ លានរៀល។

**មាត្រា៣ .-**

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................៣៤ ៨៦៩ ៣០៨,៥ លានរៀល
- អនុវត្តជាក់ស្តែង....................................៣១ ៩៨៤ ៣៧៩,៧ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុ............................................ ២ ៨៨៤ ៩២៨,៧ លានរៀល។

**មាត្រា៤ .-**

ចំណូលថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងចំណុច I នៃតារាង "**ខ១**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ចំណាយថវិកាថ្នាក់ជាតិដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង "**គ១**" និងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានបង្ហាញលម្អិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមប្រភេទនៅក្នុងតារាង "**គ២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

លទ្ធផលដែលសម្រេចបានពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្ត មិនឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១៖ ចំពោះចំណូលថវិកាត្រូវបានបង្ហាញនៅក្នុងចំណុច II នៃតារាង "**ខ១**" និងចំពោះចំណាយថវិកាត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**គ៣**" ដូចមានភ្ជាប់ជាមួយច្បាប់នេះ។

## ផ្នែកទី២
## កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាអនុវត្តឆ្លងកាត់រតនាគារជាតិ

**មាត្រា៥.-**

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................... ២០ ៧៨៤ ៦៨៦,០ លានរៀល
- អនុវត្តជាក់ស្តែង........................................ ២១ ៥៩៥ ៤០៦,៨ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានខ្ពស់ជាង

ច្បាប់ហិរញ្ញវត្ថុ...................................................... ៨១០ ៧២០,៨ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ..........................................១៩ ៧០៥ ៩៨៣,០ លានរៀល
- អនុវត្តជាក់ស្តែង.........................................២០ ៤៦៧ ០៨៦,០ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ..........................................៧៦១ ១០៣,០ លានរៀល។

២. ចំណូលមូលធន

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១ ០៧៨ ៧០៣,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................... ១ ១២៨ ៣២០,៨ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ..........................................៤៩ ៦១៧,៨ លានរៀល។

ក. ចំណូលមូលធនក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ..................................................២២១ ២០៣,០ លានរៀល
- អនុវត្តជាក់ស្តែង..................................................៥៦ ៨៨១,៩ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ១៦៤ ៣២១,១ លានរៀល។

ខ. ចំណូលមូលធនក្រៅប្រទេស(មូលនិធិទ្រទ្រង់ថវិកា)

- ច្បាប់ហិរញ្ញវត្ថុ..................................................៨៥៧ ៥០០,០ លានរៀល
- អនុវត្តជាក់ស្តែង..........................................១ ០៧១ ៤៣៨,៩ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ.................................. ២១៣ ៩៣៨,៩ លានរៀល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៦ .-**

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................... ២៩ ៤០៣ ៦៥៨,៥ លានរៀល
- អនុវត្តជាក់ស្តែង.......................................... ២៦ ៦៧០ ៨០៣,០ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុ.............................................. ២ ៧៣២ ៨៥៥,៤ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយចរន្ត
- ច្បាប់ហិរញ្ញវត្ថុ.......................................... ២១ ៣២២ ២៣១,២ លានរៀល
- អនុវត្តជាក់ស្តែង.......................................... ១៩ ៤៩៤ ១៦៧,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ១ ៨២៨ ០៦៤,០ លានរៀល។

២. ចំណាយមូលធន
- ច្បាប់ហិរញ្ញវត្ថុ.......................................... ៨ ០៨១ ៤២៧,២ លានរៀល
- អនុវត្តជាក់ស្តែង.......................................... ៧ ១៧៦ ៦៣៥,៨ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ៩០៤ ៧៩១,៤ លានរៀល។

ក. ចំណាយមូលធន សម្រាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស
- ច្បាប់ហិរញ្ញវត្ថុ.......................................... ៦ ៨៩៦ ២៣៧,២ លានរៀល
- អនុវត្តជាក់ស្តែង.......................................... ៥ ៩៩២ ៨០២,៤ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ៩០៣ ៤៣៤,៨ លានរៀល។

ខ. ចំណាយមូលធន សម្រាប់ការទូទាត់ការខ្ចី
- ច្បាប់ហិរញ្ញវត្ថុ.......................................... ១ ១៨៥ ១៩០,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................... ១ ១៨៣ ៨៣៣,៤ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ១ ៣៥៦,៦ លានរៀល។

**មាត្រា៧ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាជាក់ស្តែងឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង.......................... ២១ ៥៩៥ ៤០៦,៨ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.......................... ២៦ ៦៧០ ៨០៣,០ លានរៀល
- ឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំ..................... (-)៥ ០៧៥ ៣៩៦,២ លានរៀល។

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៧៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ មានចំនួនទឹកប្រាក់(-)៥ ០៧៥ ៣៩៦,២ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផលរបស់រតនាគារជាតិ។

# ផ្នែកទី៣
# បទប្បញ្ញត្តិស្តីពី
# និយ័តភាពូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម

**មាត្រា៨ .-**

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងយោងមាត្រា១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងយោងតាមតម្រូវការចាំបាច់ជាក់ស្តែងរបស់រាជរដ្ឋាភិបាល ដែលត្រូវបានអនុម័តយល់ព្រមលើកិច្ចប្រតិបត្តិការចំណាយឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

១-ផ្តល់ឥណទានថវិកាបន្ថែម៖

- ឥណទានថវិកាបន្ថែម.............................. ៤ ៦៧៩ ៦៣២,២២ លានរៀល
- អនុវត្តជាក់ស្តែង........................................ ៣ ៦៦៧ ៥៧៩,១២ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែម.................... ១ ០១២ ០៥៣,១០ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

ក. ផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖

- ឥណទានថវិកាបន្ថែម.............................. ៧៣៦ ៥៨២,២២ លានរៀល
- អនុវត្តជាក់ស្តែង........................................ ៧៣២ ៧២៩,១២ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែម........................ ៣ ៨៥៣,១០ លានរៀល

សម្រាប់ចំណាយដូចខាងក្រោម៖

ក.១. ចំណាយលើការអនុវត្តកម្មវិធីជំនួយសង្គមជួយជនក្រីក្រនិងងាយរងគ្រោះ៖

- ឥណទានថវិកាបន្ថែម.................................. ៣៦២ ៥៥១,០ លានរៀល
- អនុវត្តជាក់ស្តែង........................................... ៣៦២ ៥៥០,០ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែម.................................... ១,០ លានរៀល។

ក.២. ចំណាយលើការទិញមន្ទីរពេទ្យស្ត្រីនគរទេពដោយប្រើប្រភពចំណូលសប្បុរសជន៖

- ឥណទានថវិកាបន្ថែម................................ ៦២ ៥៣១,២២ លានរៀល
- អនុវត្តជាក់ស្តែង......................................... ៦២ ៥៣១,២២ លានរៀល។

ក.៣.ផ្តល់ឱ្យអគ្គិសនីកម្ពុជាខ្ចីក្នុងគោលដៅដោះស្រាយតម្រូវការថាមពលអគ្គិសនីរយៈពេលវែង៖

- ឥណទានថវិកាបន្ថែម................................ ២០៧ ៥០០,០ លានរៀល
- អនុវត្តជាក់ស្តែង......................................... ២០៣ ៦៥០,០ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែម.......................... ៣ ៨៥០,០ លានរៀល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ក.៤. ចំណាយសម្រាប់ការបង្វិលសងអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ៖

- ឥណទានថវិកាបន្ថែម.................................១០៤ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែង........................................១០៣ ៩៩៧,៩ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែម.................................២,១ លានរៀល។

ខ.ផ្តល់ជូនក្រសួងសុខាភិបាលសម្រាប់ចំណាយលើកម្មវិធីប្រយុទ្ធនិងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩៖

- ឥណទានថវិកាបន្ថែម.............................. ៣ ៩៤៣ ០៥០,០ លានរៀល
- អនុវត្តជាក់ស្តែង.........................................២ ៨៣៦ ៥៦៧,៨ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែម.......................១ ១០៦ ៤៨២,២ លានរៀល។

២.ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលឃុំ សង្កាត់៖

- ឥណទានថវិកាបន្ថែម.................................... ១៩៤ ៤៩៩,៧ លានរៀល
- អនុវត្តជាក់ស្តែង............................................ ១៩៤ ៤៩៩,៧ លានរៀល។

## ផ្នែកទី៤

## កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាអនុវត្តមិនឆ្លងកាត់តាមធនាគារជាតិ

**មាត្រា៩ .-**

ការអនុវត្តចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសអនុវត្តមិនឆ្លងកាត់តាមធនាគារជាតិ ដែលបានគ្រោងទុកចំណូលសរុបស្មើនឹងចំណាយសរុបសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ............................................ ៥ ៤៦៥ ៦៥០,០ លានរៀល
- អនុវត្តជាក់ស្តែង........................................... ៥ ៣១៣ ៥៧៦,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ១៥២ ០៧៣,៣ លានរៀល។

## ផ្នែកទី៥

## តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

**មាត្រា១០ .-**

តុល្យភាពនៃថវិកាថ្នាក់ជាតិ ដែលបានសម្រេចជាស្ថាពរសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលក្នុងប្រទេសអនុវត្តជាក់ស្តែង..................២០ ៥២៣ ៩៦៧,៩ លានរៀល
  + ចំណូលចរន្តអនុវត្តជាក់ស្តែង...................... ២០ ៤៦៧ ០៨៦,០ លានរៀល
  + ចំណូលមូលធនក្នុងប្រទេសអនុវត្តជាក់ស្តែង..............៥៦ ៨៨១,៩ លានរៀល
- ចំណាយថវិកាសរុបអនុវត្តជាក់ស្តែង................ ៣០ ៨០០ ៥៤៦,៤ លានរៀល
  + ចំណាយចរន្តអនុវត្តជាក់ស្តែង..................... ១៩ ៤៩៤ ១៦៧,២ លានរៀល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

+ ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី)

អនុវត្តជាក់ស្តែង.............................. ១១ ៣០៦ ៣៧៩,១ លានរៀល

- អតិរេកនៃថវិកាចរន្ត .............................. (+)៩៧២ ៩១៨,៨ លានរៀល
- ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ................. (-)១០ ២៧៦ ៥៧៨,៥ លានរៀល
- ហិរញ្ញប្បទាននៃឱនភាព ......................... (+)១០ ២៧៦ ៥៧៨,៥ លានរៀល
  + ហិរញ្ញប្បទានក្រៅប្រទេស...................... (+) ៥ ២០១ ១៨២,២ លានរៀល
  + ហិរញ្ញប្បទានក្នុងប្រទេស....................... (+) ៥ ០៧៥ ៣៩៦,២ លានរៀល
    • បញ្ញើរាជរដ្ឋាភិបាល.......................... (+) ៥ ០៧៥ ៣៩៦,២ លានរៀល។

តុល្យភាពនៃថវិកាថ្នាក់ជាតិ ដែលបានសម្រេចជាស្ថាពរនៃកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

## ជំពូកទី២
## កិច្ចប្រតិបត្តិការថវិកាថ្នាក់ក្រោមជាតិ
## ផ្នែកទី១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១១ .-**

ត្រូវបានយល់ព្រមលើការអនុវត្តជំពូកទី៥ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០។

លទ្ធផលដែលបានសម្រេចពីការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១៖ កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក៣**" កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក៤**" និងកិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក៥**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

## ផ្នែកទី២
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

**មាត្រា១២ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.............................................២ ២២៦ ១០៨,៩ លានរៀល
- អនុវត្តជាក់ស្តែង.......................................... ២ ៩៤៣ ៨០៦,៩ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត អនុវត្តបានខ្ពស់ជាង

ច្បាប់ហិរញ្ញវត្ថុ.............................................. ៧១៧ ៦៩៨,០ លានរៀល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ........................................ ១ ២៦៤ ៨៥០,០ លានរៀល
- អនុវត្តជាក់ស្ដែង........................................ ២ ០៤៧ ៥៩៤,៥ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ................................ ៧៨២ ៧៤៤,៥ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

- ច្បាប់ហិរញ្ញវត្ថុ........................................ ៧២៥ ៧៣០,៥ លានរៀល
- អនុវត្តជាក់ស្ដែង........................................ ៦៦៣ ២០៨,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ................................ ៦២ ៥២២,៣ លានរៀល។

ក. ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត

- ច្បាប់ហិរញ្ញវត្ថុ........................................ ១៧ ២៥៩,៦ លានរៀល
- អនុវត្តជាក់ស្ដែង........................................ ១៧ ២៥៩,៦ លានរៀល។

ខ. ការប្រគល់មុខងារសុខាភិបាល

- ច្បាប់ហិរញ្ញវត្ថុ........................................ ៧០៨ ៤៧០,៩ លានរៀល
- អនុវត្តជាក់ស្ដែង........................................ ៦៤៥ ៩៤៨,៦ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ................................ ៦២ ៥២២,៣ លានរៀល។

៣. ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

- ច្បាប់ហិរញ្ញវត្ថុ........................................ ២៣៥ ៥២៨,៤ លានរៀល
- អនុវត្តជាក់ស្ដែង........................................ ២៣៣ ០០៤,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ................................ ២ ៥២៤,២ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងតារាង "**១២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៣ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដូចមានចែងក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................ ២ ២២៦ ១០៨,៩ លានរៀល
- អនុវត្តជាក់ស្ដែង........................................ ២ ៨២៤ ៩៩២,៦ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានខ្ពស់ជាង ច្បាប់ហិរញ្ញវត្ថុ........................................ ៥៩៨ ៨៨៣,៧ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយចរន្ត

- ច្បាប់ហិរញ្ញវត្ថុ........................................ ១ ៩៧៦ ១២៧,៩ លានរៀល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- អនុវត្តជាក់ស្តែង............................................២ ៤៣៦ ៥១៣,៥ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ............................................ ៤៦០ ៣៨៥,៦ លានរៀល។

២. ចំណាយមូលធន

- ច្បាប់ហិរញ្ញវត្ថុ............................................២៤៩ ៩៨១,០ លានរៀល
- អនុវត្តជាក់ស្តែង............................................៣៨៨ ៤៧៩,១ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ............................................១៣៨ ៤៩៨,១ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិតតាមជំពូកនៅក្នុងចំណុច ១ នៃតារាង "**គ៤**" និងត្រូវបានលម្អិតតាមរដ្ឋបាលរាជធានី ខេត្ត និងតាមជំពូកនៅក្នុងតារាង "**គ៥**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៤ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង............................ ២ ៩៤៣ ៨០៦,៩ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង............................ ២ ៨២៤ ៩៩២,៦ លានរៀល
- អតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្ត..............(+)១១៨ ៨១៤,៣ លានរៀល។

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤២ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ អតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដែលមានទឹកប្រាក់ចំនួន(+)១១៨ ៨១៤,៣ លានរៀល ត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិ ដើម្បីយោងបន្តទៅឆ្នាំថវិកាខាងមុខ។

## ផ្នែកទី៣
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា១៥ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ............................................៥២៧ ៦៨៩,៩ លានរៀល
- អនុវត្តជាក់ស្តែង............................................ ៥០៩ ៨៦៧,៤ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុ............................................ ១៧ ៨២២,៥ លានរៀល

លទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ............................................ ៣០ ២១៣,៣ លានរៀល

- អនុវត្តជាក់ស្តែង............................................ ២៧ ៨២៣,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................ ២ ៣៩០,២ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

- ច្បាប់ហិរញ្ញវត្ថុ............................................ ៤៩១ ២៥១,៣ លានរៀល
- អនុវត្តជាក់ស្តែង............................................ ៤៧៧ ១៩៣,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................ ១៤ ០៥៨,០ លានរៀល។

ក. ឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក

- ច្បាប់ហិរញ្ញវត្ថុ............................................ ៣៥៧ ៤៧៩,៤ លានរៀល
- អនុវត្តជាក់ស្តែង............................................ ៣៥៥ ២៧៥,០ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................ ២ ២០៤,៤ លានរៀល។

ខ. ការប្រគល់មុខងារអប់រំ

- ច្បាប់ហិរញ្ញវត្ថុ............................................ ១៣៣ ៧៧១,៩ លានរៀល
- អនុវត្តជាក់ស្តែង............................................ ១២១ ៩១៨,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................ ១១ ៨៥៣,៦ លានរៀល។

៣. ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

- ច្បាប់ហិរញ្ញវត្ថុ............................................ ៦ ២២៥,៣ លានរៀល
- អនុវត្តជាក់ស្តែង............................................ ៤ ៨៥១,០ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................ ១ ៣៧៤,៣ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងតារាង "**ខ៣**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៦ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ............................................ ៥២៧ ៦៨៩,៩ លានរៀល
- អនុវត្តជាក់ស្តែង............................................ ៤៩៧ ៤៤៩,៤ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុ............................................ ៣០ ២៤០,៥ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិតតាមមាតិកានៅក្នុងចំណុច ២ នៃតារាង "**គ៤**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១៧ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង........................................ ៥០៩ ៨៦៧,៤ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.................................... ៤៩៧ ៤៤៩,៤ លានរៀល
- អតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុក.......................... (+)១២ ៤១៨,០ លានរៀល។

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤២ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ អតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុក ដែលមានទឹកប្រាក់ចំនួន(+)១២ ៤១៨,០លានរៀល ត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិដើម្បីយោងបន្តទៅឆ្នាំថវិកាខាងមុខ។

## ផ្នែកទី៤
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

**មាត្រា១៨ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................................ ៩០៤ ០៤៧,៧ លានរៀល
- អនុវត្តជាក់ស្តែង...................................................... ៩៥០ ២៧៤,១ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានខ្ពស់ជាង
ច្បាប់ហិរញ្ញវត្ថុ........................................................ ៤៦ ២២៦,៤ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលមិនមែនសារពើពន្ធ
- ច្បាប់ហិរញ្ញវត្ថុ........................................................ ០,០ លានរៀល
- អនុវត្តជាក់ស្តែង...................................................... ៤៦ ២២៦,៤ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ.............................................. ៤៦ ២២៦,៤ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ
- ច្បាប់ហិរញ្ញវត្ថុ........................................................ ៧០៩ ៥៤៨,០ លានរៀល
- អនុវត្តជាក់ស្តែង...................................................... ៧០៩ ៥៤៨,០ លានរៀល

៣. ចំណូលសង្កាត់ចំណុះរាជធានី
- ច្បាប់ហិរញ្ញវត្ថុ........................................................ ៣៧ ៨៣៣,០ លានរៀល
- អនុវត្តជាក់ស្តែង...................................................... ៣៧ ៨៣៣,០ លានរៀល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ខ. ចំណូលសង្កាត់ចំណុះក្រុង

- ច្បាប់ហិរញ្ញវត្ថុ......................................................៥៨ ១៩៤,០ លានរៀល
- អនុវត្តជាក់ស្តែង...................................................... ៥៨ ១៩៤,០ លានរៀល។

គ. ចំណូលឃុំ

- ច្បាប់ហិរញ្ញវត្ថុ......................................................៦១៣ ៥២១,០ លានរៀល
- អនុវត្តជាក់ស្តែង...................................................... ៦១៣ ៥២១,០ លានរៀល។

៣. អតិរេកឆ្នាំ២០២០......................................................១៩៤ ៤៩៩,៧ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិត តាមមាតិកានៅក្នុងតារាង "**ខ៤**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៩ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ......................................................៩០៤ ០៤៧,៧ លានរៀល
- អនុវត្តជាក់ស្តែង...................................................... ៧១១ ៤៧៨,៧ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុ...................................................... ១៩២ ៥៦៩,១ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយសង្កាត់ចំណុះរាជធានី

- ច្បាប់ហិរញ្ញវត្ថុ...................................................... ៤៧ ៦៤២,៦ លានរៀល
- អនុវត្តជាក់ស្តែង...................................................... ៣២ ៤៨៧,៦ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ...................................................... ១៥ ១៥៤,៩ លានរៀល។

២. ចំណាយសង្កាត់ចំណុះក្រុង

- ច្បាប់ហិរញ្ញវត្ថុ......................................................៧៦ ៥៥៤,៦ លានរៀល
- អនុវត្តជាក់ស្តែង...................................................... ៥៦ ៣៣៤,៩ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ...................................................... ២០ ២១៩,៧ លានរៀល។

៣. ចំណាយឃុំ

- ច្បាប់ហិរញ្ញវត្ថុ......................................................៧៧៩ ៨៥០,៦ លានរៀល
- អនុវត្តជាក់ស្តែង......................................................៦២២ ៦៥៦,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ...................................................... ១៥៧ ១៩៤,៤ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានបង្ហាញលម្អិត តាមមាតិកានៅក្នុងចំណុច ៣ នៃតារាង "**គ៤**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា២០ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ សម្រេចបានលទ្ធផលដូចតទៅៈ

- ចំណូលថវិកាអនុវត្តជាក់ស្តែង............................... ៩៥០ ២៧៤,១ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.............................. ៧១១ ៤៧៨,៧ លានរៀល
- អតិរេកថវិការបស់រដ្ឋបាលឃុំ សង្កាត់................. (+)២៣៨ ៧៩៥,៤ លានរៀល។

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ និងអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ អតិរេកថវិការបស់រដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២១ ដែលមានទឹកប្រាក់ចំនួន(+)២៣៨ ៧៩៥,៤លានរៀល ត្រូវយោងបន្តទៅឆ្នាំ២០២២។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៤រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២២

នស/រកម.០៣២២.០០៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ការគ្រប់គ្រងឆ្នាំ២០២១

## តារាង "ក១"

## កិច្ចប្រតិបត្តិការទូទៅថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ | ឆ្នាំ២០២១ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល = ( I.១ + II.១ ) | 26.250.336,0 | 26.908.983,5 | 102,5% | +658.647,5 |
| សរុបចំណាយ = ( I.២ + II.២ ) | 34.869.308,5* | 31.984.379,7 | 91,7% | -2.884.928,7 |
| ឱនភាពពីការអនុវត្តថវិកាក្នុងឆ្នាំ | | -5.075.396,2 | | |
| I. កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ ដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិ | | | | |
| I.១.ចំណូលថវិកា | 20.784.686,0 | 21.595.406,8 | 103,9% | +810.720,8 |
| • ចំណូលចរន្ត | 19.705.983,0 | 20.467.086,0 | 103,9% | +761.103,0 |
| • ចំណូលមូលធន | 1.078.703,0 | 1.128.320,8 | 104,6% | +49.617,8 |
| + ចំណូលមូលធនក្នុងប្រទេស | 221.203,0 | 56.881,9 | 25,7% | -164.321,1 |
| + ចំណូលមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | 857.500,0 | 1.071.438,9 | 124,9% | +213.938,9 |
| I.២.ចំណាយថវិកា | 29.403.658,5 | 26.670.803,0 | 90,7% | -2.732.855,4 |
| • ចំណាយចរន្ត | 21.322.231,2* | 19.494.167,2 | 91,4% | -1.828.064,0 |
| • ចំណាយមូលធន | 8.081.427,2 | 7.176.635,8 | 88,8% | -904.791,4 |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 6.896.237,2 | 5.992.802,4 | 86,9% | -903.434,8 |
| + ការទូទាត់ការខ្ចី | 1.185.190,0 | 1.183.833,4 | 99,9% | -1.356,6 |
| II. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | | | |
| II.១.ចំណូលមូលធនសម្រាប់គម្រោង ដោយហិរញ្ញប្បទានក្រៅប្រទេស | 5.465.650,0 | 5.313.576,7 | 97,2% | -152.073,3 |
| II.២.ចំណាយមូលធនសម្រាប់គម្រោង ដោយហិរញ្ញប្បទានក្រៅប្រទេស | 5.465.650,0 | 5.313.576,7 | 97,2% | -152.073,3 |

( * )តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន៤ ៦៧៩ ៦៣២,២២លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្ម នៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលមានចែងក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២



# ការគ្រប់គ្រងឆ្នាំ២០២១

## តារាង "ក២"

## តុល្យភាពនៃថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ហិរញ្ញប្បទាន |
|---|---|---|
| I- ចំណូលក្នុងប្រទេសសរុប | 20.523.967,9 | |
| I.១. ចំណូលចរន្ត | 20.467.086,0 | |
| I.២. ចំណូលមូលធនក្នុងប្រទេស | 56.881,9 | |
| II. ចំណាយថវិកាសរុប | 30.800.546,4 | |
| II.១. ចំណាយចរន្ត | 19.494.167,2 | |
| II.២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចីចំនួន១ ១៨៣ ៨៣៣,៤លានរៀល) | 11.306.379,1 | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 5.992.802,4 | |
| - ដោយថវិកាថ្នាក់ជាតិ | 5.448.374,4 | |
| • គម្រោងវិនិយោគផ្ទាល់ | 4.826.357,8 | |
| • បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស | 622.016,5 | |
| - ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ | 544.428,1 | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 5.313.576,7 | |
| ក. អតិរេកនៃថវិកាចរន្ត (I.១-II.១) | (+)972.918,8 | |
| ខ. ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II) | (-)10.276.578,5 | |
| III- ហិរញ្ញប្បទាននៃឱនភាព | | (+)10.276.578,5 |
| ១. ហិរញ្ញប្បទានពីក្រៅប្រទេស | | (+)5.201.182,2 |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ | | (+)1.071.438,9 |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | (+)5.313.576,7 |
| • ការទូទាត់ការខ្ចី | | (-)1.183.833,4 |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | (+)5.075.396,2 |
| • បញ្ញើរាជរដ្ឋាភិបាល | | (+)5.075.396,2 |

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

## ការគ្រប់គ្រងឆ្នាំ២០២១

## តារាង "ក៣"

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលរាជធានី ខេត្ត | ឆ្នាំ២០២១ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូលថវិកា | 2.226.108,9 | 2.943.806,9 | 132,2% | +717.698,0 |
| សរុបចំណាយថវិកា | 2.226.108,9 | 2.824.992,6 | 126,9% | +598.883,7 |
| អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ | | +118.814,3 | | |
| កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត | | | | |
| I. ចំណូលថវិកា | 2.226.108,9 | 2.943.806,9 | 132,2% | +717.698,0 |
| - ចំណូលចរន្ត | 1.264.850,0 | 2.047.594,5 | 161,9% | +782.744,5 |
| • ចំណូលសារពើពន្ធ | 1.050.323,0 | 1.790.551,0 | 170,5% | +740.228,0 |
| • ចំណូលមិនមែនសារពើពន្ធ | 214.527,0 | 257.043,4 | 119,8% | +42.516,4 |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 725.730,5 | 663.208,2 | 91,4% | -62.522,3 |
| • ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត | 17.259,6* | 17.259,6 | 100,0% | 0,0 |
| • ការប្រគល់មុខងារសុខាភិបាល | 708.470,9** | 645.948,6 | 91,2% | -62.522,3 |
| - ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 235.528,4 | 233.004,2 | 98,9% | -2.524,2 |
| II. ចំណាយថវិកា | 2.226.108,9*** | 2.824.992,6 | 126,9% | +598.883,7 |
| - ចំណាយចរន្ត | 1.976.127,9 | 2.436.513,5 | 123,3% | +460.385,6 |
| - ចំណាយមូលធន | 249.981,0 | 388.479,1 | 155,4% | +138.498,1 |

(*) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមដល់រដ្ឋបាលរាជធានី ខេត្ត ចំនួន ៤ ៤៥៣លានរៀល ក្នុងនោះ៖
(១)-ឥណទានថវិកាចំនួន២ ៦៥៥លានរៀល ផ្តល់ជូនសាលាខេត្តសៀមរាប(មូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ), (២)-ឥណទានថវិកាចំនួន ៤៩៨លានរៀល ផ្តល់ជូនរដ្ឋបាលខណ្ឌសម្រាប់ចំណាយបន្ទុកបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិកនៃការិយាល័យជំនាញដែលធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ និង(៣)-ឥណទានថវិកាចំនួន១ ៣០០លានរៀល ផ្តល់ជូនមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ចំនួន៥ កន្លែង នៃ ៤ខេត្ត

(**) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាចំនួន១៨ ០៧៦,៩លានរៀល ដើម្បីបើកប្រាក់បៀវត្សជូនមន្ត្រីរាជការសម្រាប់ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ របស់មន្ទីរសុខាភិបាលទាំង២០រាជធានី ខេត្ត ដែលរាជរដ្ឋាភិបាលបានបញ្ចូលក្របខណ្ឌក្នុងឆ្នាំ២០២១។

(***) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមដល់រដ្ឋបាលរាជធានី ខេត្ត ចំនួន២២ ៥២៩,៩លានរៀល ក្នុងនោះ៖
(១)-ឥណទានថវិកាចំនួន២ ៦៥៥លានរៀល ផ្តល់ជូនសាលាខេត្តសៀមរាប(មូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ) (២)-ឥណទានថវិកាចំនួន ៤៩៨លានរៀល ផ្តល់ជូនរដ្ឋបាលខណ្ឌសម្រាប់ចំណាយបន្ទុកបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិកនៃការិយាល័យជំនាញដែលធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ (៣)-ឥណទានថវិកាចំនួន១ ៣០០លានរៀល ផ្តល់ជូនមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ចំនួន៥ កន្លែង នៃ ៤ខេត្ត និង(៤)-ប្រកាសបន្ថែមឥណទានថវិកា ចំនួន១៨ ០៧៦,៩លានរៀល ដើម្បីបើកប្រាក់បៀវត្សជូនមន្ត្រីរាជការសម្រាប់ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ របស់មន្ទីរសុខាភិបាលទាំង២០រាជធានី ខេត្ត ដែលរាជរដ្ឋាភិបាលបានបញ្ចូលក្របខណ្ឌក្នុងឆ្នាំ២០២១។

# ការគ្រប់គ្រងឆ្នាំ២០២១

## តារាង "ក៤"

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលក្រុង ស្រុក | ឆ្នាំ២០២១ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ (-) |
| សរុបចំណូល | 527.689,9 | 509.867,4 | 96,6% | -17.822,5 |
| សរុបចំណាយ | 527.689,9 | 497.449,4 | 94,3% | -30.240,5 |
| អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ | | +12.418,0 | | |
| កិច្ចប្រតិបត្តិការនៃថវិការបស់រដ្ឋបាលក្រុង ស្រុក | | | | |
| I. ចំណូលថវិកា | 527.689,9 | 509.867,4 | 96,6% | -17.822,5 |
| - ចំណូលចរន្ត | 30.213,3 | 27.823,1 | 92,1% | -2.390,2 |
| • ចំណូលមិនមែនសារពើពន្ធ | 30.213,3* | 27.823,1 | 92,1% | -2.390,2 |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 491.251,3 | 477.193,3 | 97,1% | -14.058,0 |
| • ឧបត្ថម្ភធនដល់រដ្ឋបាលរដ្ឋបាលក្រុង ស្រុក | 357.479,4** | 355.275,0 | 99,4% | -2.204,4 |
| • ការប្រគល់មុខងារអប់រំ | 133.771,9*** | 121.918,3 | 91,1% | -11.853,6 |
| - ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 6.225,3 | 4.851,0 | 77,9% | -1.374,3 |
| II. ចំណាយថវិកា | 527.689,9 | 497.449,4 | 94,3% | -30.240,5 |
| - ចំណាយចរន្ត | 527.689,9**** | 497.449,4 | 94,3% | -30.240,5 |

(*) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែម ចំនួន១៨ ៤១១,០លានរៀល ក្នុងនោះ៖

(១)-ថវិកាចំនួន ១៧១,០លានរៀល សម្រាប់ចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញ-ចូលតែមួយសម្រាប់បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត, (២)-បន្ថែមឥណទានថវិកាសេវាអនាម័យបរិស្ថានចំនួន ៨ ០០០,០លានរៀល, (៣)-ឥណទានចំណូលសារពើពន្ធចែករំលែកពីរដ្ឋបាលខេត្ត ៤% ជូនរដ្ឋបាលក្រុង ស្រុក ចំនួន ៩ ៨៣០,០លានរៀល និង(៤)-ថវិកាចំនួន ៤១០,០លានរៀល ប្រកាសបន្ថែមឥណទានថវិកាពីការផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ចំណាយអភិវឌ្ឍន៍។

(**) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែម ចំនួន១៩ ៣៨៤,០លានរៀល ក្នុងនោះ៖

(១)-ថវិកាចំនួន ៨ ០៣១,០លានរៀល ប្រកាសបន្ថែមឥណទានការិយាល័យជំនាញ ២០វិស័យ ដែលសមាហរណកម្មចូលរចនាសម្ព័ន្ធក្រុង ស្រុក និង(២)- ថវិកាចំនួន ១១ ៣៥៣,០លានរៀល ប្រកាសបន្ថែមឥណទានថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ចំណាយអភិវឌ្ឍន៍។

(***) តួលេខនេះបូកបន្ថែមថវិកាចំនួន ៨៤,៩លានរៀល សម្រាប់ការផ្ទេរមុខងារអប់រំនៅខេត្តបាត់ដំបង។

(****) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែម ចំនួន៣៧ ៨៧៩,៩លានរៀល ក្នុងនោះ៖

(១)-ចំណូលសារពើពន្ធចែលរំលែកពីរដ្ឋបាលខេត្ត៤% ជូនរដ្ឋបាលក្រុង ស្រុក ចំនួន ៩ ៨៣០,០លានរៀល, (២)-ថវិកាសេវាអនាម័យបរិស្ថានចំនួន៨ ០០០,០លានរៀល, (៣)-ថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន១១ ៣៥៣,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍, (៤)-ថវិកាពីការផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទចំនួន៤១០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍, (៥)-ថវិកាការិយាល័យជំនាញ២០ វិស័យ ដែលសមាហរណកម្មចូលរចនាសម្ព័ន្ធក្រុង ស្រុក ចំនួន ៨ ០៣១លានរៀល (៦)-ថវិកាសម្រាប់ការផ្ទេរមុខងារអប់រំនៅខេត្តបាត់ដំបង ចំនួន៨៤,៩លានរៀល និង(៧)-ថវិកាចំនួន ១៧១,០លានរៀល សម្រាប់ចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញ-ចូលតែមួយសម្រាប់បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២១

## តារាង "ក៥"

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលឃុំ សង្កាត់ | ឆ្នាំ២០២១ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ (-) |
| សរុបចំណូល | 904,047.7 | 950,274.1 | 105.1% | +46,226.4 |
| សរុបចំណាយ | 904,047.7 | 711,478.7 | 78.7% | -192,569.0 |
| អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ | | +238,795.4 | | |
| កិច្ចប្រតិបត្តិការនៃថវិការបស់រដ្ឋបាលឃុំ សង្កាត់ | | | | |
| I. ចំណូលថវិកា | 904,047.7 | 950,274.1 | 105.1% | +46,226.4 |
| - ចំណូលមិនមែនសារពើពន្ធ | 0.0 | 46,226.4 | | +46,226.4 |
| • ចំណូលសង្កាត់ចំណុះរាជធានី | 0.0 | 126.5 | | +126.5 |
| • ចំណូលសង្កាត់ចំណុះក្រុង | 0.0 | 4,123.2 | | +4,123.2 |
| • ចំណូលឃុំ | 0.0 | 41,976.7 | | +41,976.7 |
| - ចំណូលឧបត្ថម្ភពីថវិកាជាតិសរុប | 709,548.0 | 709,548.0 | 100.0% | 0.0 |
| • ចំណូលសង្កាត់ចំណុះរាជធានី | 37,833.0 | 37,833.0 | 100.0% | 0.0 |
| • ចំណូលសង្កាត់ចំណុះក្រុង | 58,194.0 | 58,194.0 | 100.0% | 0.0 |
| • ចំណូលឃុំ | 613,521.0 | 613,521.0 | 100.0% | 0.0 |
| - អតិរេកឆ្នាំ២០២០ | 194,499.7* | 194,499.7 | 100.0% | 0.0 |
| II. ចំណាយថវិកា | 904,047.7 | 711,478.7 | 78.7% | -192,569.1 |
| - ចំណាយសរុប | 904,047.7 | 711,478.7 | 78.7% | -192,569.0 |
| • ចំណាយសង្កាត់ចំណុះរាជធានី | 47,642.6 | 32,487.6 | 68.2% | -15,155.0 |
| • ចំណាយសង្កាត់ចំណុះក្រុង | 76,554.6 | 56,334.9 | 73.6% | -20,219.7 |
| • ចំណាយឃុំ | 779,850.6 | 622,656.2 | 79.8% | -157,194.4 |

(*) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន១៩៤ ៤៩៩,៧លានរៀល ដោយយោងការធ្វើនិយ័តការូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។



# ការគ្រប់គ្រងឆ្នាំ២០២១
## តារាង "ខ១"
## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២១ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបរួមចំណូលថវិកា (I+II) | | | | 26.250.336.000.000 | 26.908.983.514.674 | 102,5% | +658.647.514.674 |
| I. សរុបចំណូលអនុវត្តឆ្លងកាត់រតនាគារជាតិ (ក+ខ) | | | | 20.784.686.000.000 | 21.595.406.812.582 | 103,9% | +810.720.812.582 |
| ក្នុងនោះ ចំណូលក្នុងប្រទេស | | | | 19.927.186.000.000 | 20.523.967.954.878 | 103,0% | +596.781.954.878 |
| ក. សរុបចំណូលចរន្ត (ក្រុមទី១) | | | | 19.705.983.000.000 | 20.467.086.043.145 | 103,9% | +761.103.043.145 |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 19.705.983.000.000 | 20.467.086.043.145 | 103,9% | +761.103.043.145 |
| | ប្រភេទទី១: ចំណូលសារពើពន្ធ | | | 17.520.000.000.000 | 18.496.593.033.291 | 105,6% | +976.593.033.291 |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 15.224.600.000.000 | 16.346.034.265.051 | 107,4% | +1.121.434.265.051 |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 4.304.000.000.000 | 5.937.125.606.100 | 137,9% | +1.633.125.606.100 |
| | | 70011 | ពន្ធលើប្រាក់ចំណូល(រូបវន្តបុគ្គល) | 144.000.000.000 | 64.952.624.951 | 45,1% | -79.047.375.049 |
| | | 70012 | ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) | 3.410.000.000.000 | 4.879.046.202.208 | 143,1% | +1.469.046.202.208 |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 750.000.000.000 | 993.126.778.941 | 132,4% | +243.126.778.941 |
| | 7002 | | ពន្ធប្រយោល | 6.276.800.000.000 | 5.998.641.590.360 | 95,6% | -278.158.409.640 |
| | | 70021 | អាករលើផលរបរ | 0 | 98.634 | | +98.634 |
| | | 70022 | អាករលើតម្លៃបន្ថែម | 2.640.000.000.000 | 2.487.204.588.113 | 94,2% | -152.795.411.887 |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 841.700.000.000 | 778.657.973.047 | 92,5% | -63.042.026.953 |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 2.795.100.000.000 | 2.732.778.930.566 | 97,8% | -62.321.069.434 |
| | 7003 | | អាករពិសេស | 4.508.800.000.000 | 4.264.131.219.213 | 94,6% | -244.668.780.787 |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 870.000.000.000 | 732.077.532.581 | 84,1% | -137.922.467.419 |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 538.000.000.000 | 677.307.517.895 | 125,9% | +139.307.517.895 |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 3.025.800.000.000 | 2.801.306.503.444 | 92,6% | -224.493.496.556 |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 75.000.000.000 | 53.439.665.293 | 71,3% | -21.560.334.707 |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 135.000.000.000 | 146.135.849.378 | 108,2% | +11.135.849.378 |
| | | 70082 | ប្រាក់ទោសទណ្ឌសារពើពន្ធ | 135.000.000.000 | 146.135.849.378 | 108,2% | +11.135.849.378 |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2.295.400.000.000 | 2.150.558.768.240 | 93,7% | -144.841.231.760 |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 2.283.700.000.000 | 2.106.892.723.331 | 92,3% | -176.807.276.669 |
| | | 71001 | ពន្ធគយពីការនាំចូល | 1.546.600.000.000 | 1.404.128.205.619 | 90,8% | -142.471.794.381 |
| | | 71002 | កម្រៃពីការងារគយ | 32.800.000.000 | 23.710.886.387 | 72,3% | -9.089.113.613 |
| | | 71003 | ពន្ធគយលើផលិតផលប្រេងសិលា | 331.000.000.000 | 264.907.678.580 | 80,0% | -66.092.321.420 |
| | | 71004 | អាករបន្ថែមលើផលិតផលប្រេងសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 361.000.000.000 | 394.461.373.426 | 109,3% | +33.461.373.426 |
| | | 71005 | ផលពីការលក់ទំនិញរឹបអូស និងទំនិញគ្មានការទាមទារ | 300.000.000 | 82.933.401 | 27,6% | -217.066.599 |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 12.000.000.000 | 19.601.645.918 | 163,3% | +7.601.645.918 |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 11.700.000.000 | 43.666.044.909 | 373,2% | +31.966.044.909 |
| | | 71011 | អាករលើការនាំចេញឈើ | 4.500.000.000 | 9.842.421.002 | 218,7% | +5.342.421.002 |
| | | [illegible] | អាករលើការនាំចេញកៅស៊ូ | 2.700.000.000 | 21.800.738.531 | 807,4% | +19.100.738.531 |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | 4.300.000.000 | 11.878.252.666 | 276,2% | +7.578.252.666 |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | 200.000.000 | 144.632.710 | 72,3% | -55.367.290 |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២១

## តារាង "ខ១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២១ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| | ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | | | 2.185.983.000.000 | 1.970.493.009.854 | 90,1% | -215.489.990.146 |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 205.084.500.000 | 414.997.424.772 | 202,4% | +209.912.924.772 |
| | 7200 | | ផលសម្បទាន | 185.140.500.000 | 123.038.714.000 | 66,5% | -62.101.786.000 |
| | | 72002 | ផលពីព្រៃឈើ | 9.492.000.000 | 16.473.256.507 | 173,5% | +6.981.256.507 |
| | | 72003 | សម្បទានប្រេងកាត | 56.560.500.000 | 0 | 0.0% | -56.560.500.000 |
| | | 72004 | សម្បទានរ៉ែ | 99.601.000.000 | 96.119.202.882 | 96,5% | -3.481.797.118 |
| | | 72005 | សម្បទានដីសេដ្ឋកិច្ច | 11.500.000.000 | 7.653.460.902 | 66,6% | -3.846.539.098 |
| | | 72008 | ផលសម្បទានផ្សេងៗ | 7.987.000.000 | 2.792.793.709 | 35,0% | -5.194.206.291 |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | 19.944.000.000 | 291.958.710.772 | 1.463,9% | +272.014.710.772 |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 19.944.000.000 | 291.958.710.772 | 1.463,9% | +272.014.710.772 |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.668.810.200.000 | 1.083.623.615.663 | 64,9% | -585.186.584.337 |
| | 7300 | | ផលទុនតាមវិស័យ | 627.068.500.000 | 454.264.434.590 | 72,4% | -172.804.065.410 |
| | | 73001 | ផលទុនអាកាសចរណ៍ស៊ីវិល | 131.316.000.000 | 22.360.169.491 | 17,0% | -108.955.830.509 |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 197.900.000.000 | 2.877.612.665 | 1,5% | -195.022.387.335 |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 8.733.000.000 | 90.955.377 | 1,0% | -8.642.044.623 |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 282.569.000.000 | 421.268.423.409 | 149,1% | +138.699.423.409 |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 939.600.000 | 521.948.000 | 55,6% | -417.652.000 |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 0 | 84.590.500 | | +84.590.500 |
| | | 73008 | ផលទុនផ្សេងៗទៀត | 5.610.900.000 | 7.060.735.148 | 125,8% | +1.449.835.148 |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 110.033.200.000 | 86.689.612.701 | 78,8% | -23.343.587.299 |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | 120.000.000 | 33.409.850 | 27,8% | -86.590.150 |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 109.744.200.000 | 86.441.922.851 | 78,8% | -23.302.277.149 |
| | | 73014 | ការលក់ផលិតផលកសិកម្ម | 139.000.000 | 13.120.000 | 9,4% | -125.880.000 |
| | | 73015 | ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬខូច | 30.000.000 | 189.010.000 | 630,0% | +159.010.000 |
| | | 73016 | ការលក់ឧបករណ៍អេឡិចត្រូនិចចាស់ៗ ឬខូច | 0 | 12.150.000 | | +12.150.000 |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (១) | 71.518.600.000 | 93.024.990.666 | 130,1% | +21.506.390.666 |
| | | 73022 | ផលពីការចុះបញ្ជីគណបក្សនយោបាយ | 6.000.000 | 9.000.000 | 150,0% | +3.000.000 |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 29.565.200.000 | 32.061.028.836 | 108,4% | +2.495.828.836 |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 2.095.300.000 | 1.556.910.672 | 74,3% | -538.389.328 |
| | | 73026 | ចំណូលពីប្រដាប់ភ្លើ | 4.559.300.000 | 5.622.017.967 | 123,3% | +1.062.717.967 |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេង | 35.292.800.000 | 53.776.033.191 | 152,4% | +18.483.233.191 |
| | 7304 | | ការផ្តល់សេវាកម្ម | 41.796.600.000 | 37.761.835.763 | 90,3% | -4.034.764.237 |
| | | 73042 | កម្រៃនៃការថែទាំ | 11.956.200.000 | 7.769.006.595 | 65,0% | -4.187.193.405 |
| | | 73044 | [illegible]សំណង់ | 12.000.000.000 | 11.225.605.974 | 93,5% | -774.394.026 |
| | | 73045 | សេវាផ្តល់ព្រឹត្តិបត្រថ្កោលទោស | 2.702.400.000 | 2.491.568.300 | 92,2% | -210.831.700 |
| | | 73047 | សេវា[illegible]ពន្ធប្រថាប់ត្រា | 3.000.000.000 | 4.276.986.300 | 142,6% | +1.276.986.300 |



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២១
## តារាង "ខ១"
## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២១ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 12.138.000.000 | 11.998.668.594 | 98,9% | -139.331.406 |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | 266.073.900.000 | 152.134.849.159 | 57,2% | -113.939.050.841 |
| | | 73061 | ចំណូលពីកាតព្វកិច្ចកាស៊ីណូ | 198.089.000.000 | 11.716.581.003 | 5,9% | -186.372.418.997 |
| | | 73062 | ចំណូលពីកាតព្វកិច្ចឆ្នោត | 3.137.000.000 | 3.986.892.092 | 127,1% | +849.892.092 |
| | | 73065 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | 35.000.000 | 50.000.000 | 142,9% | +15.000.000 |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 44.812.900.000 | 106.874.451.268 | 238,5% | +62.061.551.268 |
